**នៅចំពោះមុខ អង្គជំនុំជម្រះសាលាដំបូង**

**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

**ព័ត៌មានពិស្តារអំពីការដាក់ឯកសារ**

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 18-Jul-2011, 09:37
CMS/CFO: Uch Arun

សំណុំរឿងលេខ៖ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អជប

ភាគីដាក់ឯកសារ៖ សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី

ដាក់ជូន៖ អង្គជំនុំជម្រះសាលាដំបូង

ភាសាដើម៖ បារាំង

កាលបរិច្ឆេទឯកសារ៖ ថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០១១

**<u>ចំណាត់ថ្នាក់ឯកសារ</u>**

ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ៖ សាធារណៈ

ចំណាត់ថ្នាក់ឯកសារដោយ កសចស៖ **សាធារណៈ/Public**

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់ណ្តោះអាសន្ន៖

ឈ្មោះមន្ត្រីកត់ត្រា៖

ហត្ថលេខា៖

---

**សារណាបន្ទាន់ស្នើសុំអង្គជំនុំជម្រះសាលាដំបូងឲ្យកែតម្រូវអនុស្សារណៈ** E62/3/10

(**អនុស្សារណៈចាស់លេខ**E106)

---

**<u>ដាក់ដោយ៖</u>**

**សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី**

ពេជ អង្គ

Elisabeth SIMONNEAU-FORT

**សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណី ៖**

គឹម ម៉េងឃី

ម៉ុច សុវណ្ណារី

ជេត វណ្ណលី

ហុង គឹមសួន

ឡោ ជុនធី

ស៊ីន សុវ៉ន

សំ សុគង់

វ៉េន ពៅ

ទី ស្រីនណា

Evelyne BOILEAU-BRANDOMIR
Philippe CANONNE
Annie DELAHAIE

**<u>ដាក់ជូន៖</u>**

**អង្គជំនុំជម្រះសាលាដំបូង**

ចៅក្រម និល ណុន ជាប្រធាន

ចៅក្រម Silvia CARTWRIGHT

ចៅក្រម យ៉ា សុខន

ចៅក្រម Jean-Marc LAVERGNE

ចៅក្រម ធូ មណី

**ចំលងជូន ៖**

**សហព្រះរាជអាជ្ញា ៖**

ជា លាង

Andrew CAYLEY

**ជនជាប់ចោទ**

នួន ជា

អៀង សារី

Laure DESFORGES
Ferdinand DJAMMEN NZEPA
Nicole DUMAS
Isabelle DURAND
Françoise GAUTRY
Martine JACQUIN
Daniel LOSQ
Christine MARTINEAU
Barnabé NEKUIE
Elisabeth RABESANDRATANA
Fabienne TRUSSES NAPROUS
Silke STUDZINSKY
Emmanuel ALTIT
Pascal AUBOIN
Olivier BAHOUGNE
Patrick BAUDOIN
Marie GUIRAUD
Emmanuel JACOMY
Madhev MOHAN
Lyma Thuy NGUYEN
Julien RIVET
Nushin SARKARATI

អៀង ធីរិទ្ធ
ខៀវ សំផន

**សហមេធាវីការពារក្តីជនជាប់ចោទ**

សុន អរុណ
Michiel PESTMAN
អាង ឧត្តម
Michael G.KARNAVAS
ផាត់ ពៅស៊ាង
Diana ELLIS
ស ស្វវាន
Jacques VERGÈS

## I. ការរំលឹកពីអង្គហេតុ និងនីតិវិធី

1. វិធាន ៨៦ នៃវិធានផ្ទៃក្នុងចែងថា « នៅគ្រប់ពេលវេលា សហព្រះរាជអាជ្ញា និងមេធាវីរបស់ភាគីទាំងអស់ត្រូវមានសិទ្ធិពិនិត្យមើល និងថតចម្លងសំណុំរឿង ដោយស្ថិតក្រោមការត្រួតពិនិត្យរបស់ក្រឡាបញ្ជីនៃអង្គជំនុំជម្រះសាលាដំបូងនៅម៉ោងធ្វើការ និងត្រូវគោរពទៅតាមលក្ខខណ្ឌតម្រូវសម្រាប់ដំណើរការល្អរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា» ។

2. នៅថ្ងៃទី២ ខែកុម្ភៈ ឆ្នាំ២០១១ សហមេធាវីការពារក្តី អៀង ធីរិទ្ធ បានដាក់សំណើ « ស្នើសុំចាត់តាំងអ្នកជំនាញផ្នែកវិកលចរិត(NEUROPSYCHIATRIST) ដើម្បីវាយតម្លៃសម្បទារបស់អ្នកស្រី អៀង ធីរិទ្ធ ក្នុងការចូលរួមសវនាការជម្រះក្តី ជាមួយឧបសម្ព័ន្ធ និងឧបសម្ព័ន្ធ ឃ សម្ងាត់បំផុតដែលមានព័ត៌មានឯកសិទ្ធិ » (E52) ។

3. អំឡុងពេលថ្ងៃទីមួយនៃសវនាការបឋមនៅថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០១១ ប្រធានអង្គជំនុំជម្រះសាលាដំបូងបានសម្រេចថារបាយការណ៍វេជ្ជសាស្ត្ររបស់វេជ្ជបណ្ឌិត Campbell ទាក់ទងនឹងជនជាប់ចោទបីរូបក្នុងចំណោមជនជាប់ចោទទាំងអស់ ត្រូវដាក់ចូលក្នុងសំណុំរឿងជាប្រភេទឯកសារសម្ងាត់កាលពីថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០១១ ។ ជាការឆ្លើយតប សហមេធាវីការពារ អៀង ធីរិទ្ធ បានដាក់ឯកសារជំទាស់មួយ ដែលតាមរយៈឯកសារនេះបញ្ជាក់ថា មានតែសហព្រះរាជអាជ្ញាទេមានសិទ្ធិមើលរបាយការណ៍វេជ្ជសាស្ត្រនេះ ហើយបានគូសបញ្ជាក់ទៀតថាដើមបណ្តឹងរដ្ឋប្បវេណីមិនមានផលប្រយោជន៍ស្របច្បាប់ណាមួយដើម្បីដឹងពីឯកសារនេះទេ[1] ។ សហមេធាវីការពារក្តី នួន ជា បានយល់ស្របដាក់រួមគ្នានូវសេចក្តីជំទាស់របស់សហមេធាវីការពារក្តី អៀង ធីរិទ្ធ[2] ។

4. នៅក្នុង « អនុស្សារណៈជូនចំពោះមេធាវីរបស់ភាគី ( អនុស្សារណៈE106 (E62/3/10)»ចុះនៅថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០១១[3] អង្គជំនុំជម្រះសាលាដំបូង («អង្គជំនុំជម្រះ»)បានសម្រេចដាក់ក្នុងប្រភេទថ្នាក់សម្ងាត់បំផុតនូវរាល់របាយការណ៍វេជ្ជសាស្ត្រទាក់ទងនឹង អៀង ធីរិទ្ធ និងនួន ជារហូតដល់មានសេចក្តីសម្រេចថ្មីរបស់ អង្គជំនុំជម្រះ ។ ផ្ទុយទៅវិញ អង្គជំនុំជម្រះ បញ្ជាក់ថា « វាមាន

---

[1]សេចក្តីជំទាស់របស់ក្រុមមេធាវីការពារក្តីទៅនឹងការប្រកាសរបស់អង្គជំនុំជម្រះសាលាដំបូង អំពីការដាក់របាយការណ៍វេជ្ជសាស្ត្ររបស់វេជ្ជបណ្ឌិត CAMPBELL ទៅក្នុងផ្នែកបំសម្ងាត់™នៃសំណុំរឿង ចុះនៅថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១១ ត្រង់ខថាខណ្ឌ១២។

[2] អនុស្សារណៈជូនចំពោះមេធាវីរបស់ភាគីE106 ចុះថ្ងៃទី៦ កក្កដា ២០១១ (បន្ទាប់ពីអង្គជំនុំជម្រះកែប្រែលេខយោងអនុស្សារណៈ មានលេខយោងថ្មីE62/3/10)

[3] ដូចខាងលើ

សារៈសំខាន់ណាស់ដែលថាភាគីទាំងអស់មានឱកាសដើម្បីផ្តល់យោបល់គាំទ្រ ឬជំទាស់ទៅនឹងការយល់ឃើញផ្នែកវេជ្ជសាស្ត្ររបស់អ្នកជំនាញ»[4]។

5. អង្គជំនុំជម្រះសាលាដំបូងសម្រេចកម្រិតការផ្តល់នូវបណ្តារបាយការណ៍ទាំងនេះដល់បណ្តាមេធាវីរបស់ភាគីនានា ប៉ុន្តែបានទុក«ឱកាសដល់ពួកគេដើម្បីពិនិត្យមើលរបាយការណ៍ទាំងមូល និងដើម្បីធ្វើការចង្អុលបង្ហាញអំពីការគាំទ្រឬ ជំទាស់ ទៅលើសំនើរបស់ អៀង ធីរិទ្ធ និង នួន ជា»[5] ។ អង្គជំនុំជម្រះបញ្ជាក់ទៀតថា « មានតែសហព្រះរាជអាជ្ញា មេធាវីភាគីការពាររបស់ជនជាប់ចោទម្នាក់ៗ និង មេធាវីនាំមុខរបស់ដើមបណ្តឹងរដ្ឋប្បវេណីប៉ុណ្ណោះនឹងទទួលបានរបាយការណ៍របស់អ្នកជំនាញទាក់ទងទៅនឹងជនជាប់ចោទ អៀង ធីរិទ្ធ និង នួន ជា ជាអត្ថបទចម្លងពេញលេញ»។

6. អង្គជំនុំជម្រះបញ្ជាក់បន្ថែមថា សហមេធាវីនាំមុខដើមបណ្តឹងរដ្ឋប្បវេណីអាចផ្តល់នូវសេចក្តីចំលងមួយច្បាប់នៃរបាយការណ៍ទាំងនេះ ទៅឲ្យមេធាវីរបស់ដើមបណ្តឹងរដ្ឋប្បវេណី តែម្នាក់គត់ប៉ុណ្ណោះប្រសិនមានការព្រមព្រៀងស្របតាមវិធាន១២ស្ទួនពីរ(៥)(ខ) និង(៦)នៃវិធានផ្ទៃក្នុង ដើម្បីធ្វើការងារពាក់ព័ន្ធនឹងការគាំទ្ររបស់មេធាវីដើមបណ្តឹងរដ្ឋប្បវេណីចំពោះសហមេធាវីនាំមុខ ក្រោមទម្រង់ជាសារណាលាយលក្ខណ៍អក្សរ ឬបទអន្តរាគមន៍នានាដោយផ្ទាល់មាត់ចំពោះមុខ អង្គជំនុំជម្រះ ។

II. **ការពិភាក្សា ៖**

**លើលក្ខណៈវិនិច្ឆ័យនៃឯកសារសម្ងាត់បំផុត**

7. អង្គជំនុំជម្រះពិចារណាឃើញថារាល់របាយការណ៍វេជ្ជសាស្ត្រត្រូវតែដាក់ចូលក្នុងថ្នាក់ឯកសារសម្ងាត់បំផុត ដោយមូលហេតុនៃសារៈសំខាន់ជាសារវ័ន្តរបស់ឯកសារក្នុងតំណាក់កាលនិតីវិធីពេលបច្ចុប្បន្ននេះ។ ដោយមើលក្នុងសេចក្តីណែនាំអនុវត្តលើ « ចំណាត់ថ្នាក់ និងការរក្សាទុករាល់ភស្តុតាងទៅក្នុងសំណុំរឿង »[6] ។ « ពាក្យ " សម្ងាត់បំផុត" មានន័យថារាល់ឯកសារទាំងនេះ មានតែចៅក្រមប៉ុណ្ណោះដែលមានសិទ្ធិចូលមើល និងរួមទាំងបុគ្គលទាំងឡាយណាដែលជាបុគ្គលិករបស់អ.វ.ត.កផងដែរ ។ ចំពោះអ្នកទាំងនេះ សិទ្ធិចូលមើលឯកសារត្រូវបានផ្តល់ជាលាយលក្ខណ៍អក្សរដោយអ.វ.ត.ក ដើម្បីពួកគេបំពេញភារកិច្ចបាន ។ » ចំណាត់ថ្នាក់សម្ងាត់បំផុតចំពោះមុខអ.វ.ត.ក

[4] ដូចខាងលើ

[5] ដូចខាងលើ

[6] ចំណាត់ថ្នាក់ឯកសារ និងការថែរក្សាភស្តុតាងនៃសំនុំរឿង សេចក្តីណែនាំអនុវត្ត 004/2009 ចុះថ្ងៃទី៥ ខែមិថុនា ឆ្នាំ២០០៩ មាត្រា២ (d)(iii)

ត្រូវគ្នានឹងសេចក្តីជូនដំណឹងចំពោះតែទៅក្រុមនៃស្ថាប័នយុត្តាធិការពាក់ព័ន្ធប៉ុណ្ណោះ ហើយភាគីដែលអាចមានសិទ្ធិចូលមើលបាននោះគឺវាអាស្រ័យលើឆន្ទានុសិទ្ធិរបស់អង្គជំនុំជម្រះ ។

8. ចំពោះអនុស្សារណៈE106 (E62/3/10) អង្គជំនុំជម្រះបានសម្រេចថា ដោយយល់ឃើញពីសារៈប្រយោជន៍រាល់ឯកសារដែលកំពុងលើកឡើង ដូច្នេះសេចក្តីជូនដំណឹងមួយត្រូវធ្វើជូនចំពោះសហព្រះរាជអាជ្ញា និងចំពោះគ្រប់មេធាវីតែប៉ុណ្ណោះ ប៉ុន្តែមិនត្រូវផ្តល់ឲ្យជនជាប់ចោទ និងដើមបណ្តឹងរដ្ឋប្បវេណីទេ ។ របាយការណ៍ទាំងនេះមានជាប់ពាក់ព័ន្ធនឹងផលប្រយោជន៍ជាសារវ័ន្តរបស់គ្រប់ភាគីក្នុងដំណើរការសំណុំរឿង ។ ការណ៍នេះ វាអាចបណ្តាលឲ្យដកចេញជនជាប់ចោទម្នាក់ ឬច្រើននាក់ ហើយនាំឲ្យកែប្រែសិទ្ធិរបស់ភាគីដទៃទៀត អាចជាជនជាប់ចោទ ឬជាដើមបណ្តឹងរដ្ឋប្បវេណី។ ដូចនេះ វាសំខាន់ណាស់ដែលមេធាវីគ្រប់ភាគីទាំងអស់ដោយគ្មានការបែងចែក អាចមើលឯកសារទាំងនេះ ដើម្បីបំពេញភារកិច្ចរបស់ខ្លួន ។

9. ដោយឈរលើលក្ខណៈវិនិច្ឆ័យសម្ងាត់បំផុតនៃឯកសារ អង្គជំនុំជម្រះធ្វើការញែកពីគ្នារវាង សហមេធាវីនាំមុខដើមបណ្តឹងរដ្ឋប្បវេណី និងមេធាវីដើមបណ្តឹងរដ្ឋប្បវេណីក្នុងកាលៈទេសៈខ្លះ ។ វិបាកគឺសេចក្តីជូនដំណឹងពីឯកសារសម្ងាត់បំផុតទៅគ្រប់មេធាវីទាំងអស់ លើកលែងតែ មេធាវីដើមបណ្តឹងរដ្ឋប្បវេណី ។

**លើសេចក្តីជូនដំណឹងអំពីឯកសារនានាក្នុងសំណុំរឿងទៅគ្រប់ភាគីទាំងអស់**

10. ការរិតត្បិតពីសេចក្តីជូនដំណឹង ដោយជូនចំពោះតែសហមេធាវីនាំមុខដើមបណ្តឹងរដ្ឋប្បវេណី សម្រេចដោយអង្គជំនុំជម្រះបណ្តាលឲ្យមានការរំលោភយ៉ាងធ្ងន់ធ្ងរគោលការណ៍គ្រឹះក្នុងការមើលសំណុំរឿងរបស់មេធាវីក្នុងដំណើការនីតិវិធី។ ការរិតត្បិតនេះមិនសមហេតុផល និងមិនមានមូលដ្ឋានច្បាប់ទាល់តែសោះ ។

11. សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី និងមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីយល់ស្របគ្នា តាមរយៈសារណានេះថាអនុស្សារណៈE106 (E62/3/10) របស់អង្គជំនុំជម្រះសាលាដំបូង បង្កើតឲ្យមានប្រព័ន្ធរើសអើង ជាបដិប្បញត្តិ និងផ្ទុយទៅនឹងវិធានផ្ទៃក្នុងរបស់អង្គជំនុំជម្រះ

វិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក) និងគោលការណ៍សមភាពនៃកម្លាំងដែលត្រូវបានទទួលស្គាល់ជាអន្តរជាតិ[7] ។

12. ដូចនេះ សហមេធាវីនាំមុខ និងមេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណីស្នើសុំ អង្គជំនុំជម្រះឲ្យគោរពសិទ្ធិរបស់មេធាវីដើមបណ្ដឹងរដ្ឋប្បវេណី ដើម្បីទទួលបានការជូនដំណឹងអំពីរាល់គ្រប់ឯកសារដូចគ្នានឹងមេធាវីរបស់ភាគីផ្សេងទៀត ។

**លើភាពជាតំណាងស្របច្បាប់ដើមបណ្ដឹងរដ្ឋប្បវេណីក្នុងដំណាក់កាលនៃសំនុំរឿង**

13. យោងទៅតាមវិធាន២៣ស្ទួនពីរ(២) នៃវិធានផ្ទៃក្នុងបានបញ្ញត្តិថា« នៅពេលដើមបណ្ដឹងរដ្ឋប្បវេណីត្រូវបានតំណាងដោយមេធាវី សិទ្ធិរបស់ដើមបណ្ដឹងរដ្ឋប្បវេណីនឹងត្រូវបានអនុវត្តតាមរយៈមេធាវីនោះ[...]»។

14. បើយោងទៅតាមវិធាន១២ស្ទួនពីរ (៥) សហមេធាវីនាំមុខធានានូវការរៀបចំឲ្យមានប្រសិទ្ធិភាពក្នុងការតំណាងដើមបណ្ដឹងរដ្ឋប្បវេណីនៅក្នុងដំណាក់កាលនៃសំនុំរឿង និងក្នុងដំណាក់កាលផ្សេងៗក្រោយទៀត។ទោះបីជាសហមេធាវីនាំមុខជាអ្នកបើកដំបូងនៃនីតិវិធីអ.វ.ត.ក ក៏ដោយ ក៏មេធាវីដើមបណ្ដឹងរដ្ឋប្បវេណីនៅតែជាតួអង្គដ៏មានសារៈសំខាន់ក្នុងការចូលរួម និងតំណាងផលប្រយោជន៍របស់ដើមបណ្ដឹងរដ្ឋប្បវេណីគ្រប់ដំណាក់កាលទាំងអស់នៃនីតិវិធី។ អាស្រ័យហេតុនេះហើយ មេធាវីដើមបណ្ដឹងរដ្ឋប្បវេណីត្រូវមានសិទ្ធិក្នុងការទទួលបាននូវព័ត៌មានសមស្របដើម្បីធានាបាននូវការការពារមួយជាក់ច្បាស់ក្នុងការគោរពផលប្រយោជន៍កូនក្ដីរបស់ពួកគេ។ វាមិនសមរម្យនោះទេ ដែលវិនិច្ឆ័យថា សហមេធាវីនាំមុខអាចនឹងគោរពបាននូវកាតព្វកិច្ចចម្បងរបស់ខ្លួនបាន ដែលជាការប្រឹក្សា ជាអ្នកស្វែងរកការសម្រេចជាឯកច្ឆ័ន្ទ និងជាការសម្របសម្រួលភាពជាដំណាង ព្រមទាំងកាតព្វកិច្ចផ្សេងទៀតចេញវិធាន១២ស្ទួន (៣) នៅខណៈពេលដែលមេធាវីដើមបណ្ដឹងរដ្ឋប្បវេណីមិនទទួលបាននូវឯកសារនៃសំនុំរឿងនោះ។ សហមេធាវីនាំមុខយល់ថា អនុស្សារណៈ E106 (E62/3/10) ប៉ះពាល់យ៉ាងធ្ងន់ធ្ងរនូវបុព្វសិទ្ធិរបស់មេធាវីដើមបណ្ដឹងរដ្ឋប្បវេណី ដោយសារការដកហូតសិទ្ធិរបស់ពួកគេក្នុងការមើលឯកសារ ស្របពេលដែលមេធាវីការពារក្ដី និងសហព្រះរាជអាជ្ញាអាចមើលឯកសារទាំងនេះ ដោយគ្មានការរិតត្បិតអ្វីទាំងអស់នោះ។ វិធាន១២ស្ទួន (៣)បាន

[7] សាលដីការសាលាឧទ្ធរណ៍នៃតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតយូហ្គោស្លាវី ៖ សំនុំរឿង រដ្ឋអាជ្ញា ប្រឆាំងនឹង Dusko Tadic ចុះថ្ងៃទី១៥ កក្កដា ១៩៩៩ IT-94-1-Q **កថាខណ្ឌ** 48

បញ្ជាក់ថា « ការងារជាដំបូងរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីត្រូវស្វែងរកទស្សនៈផ្សេងៗពីមេធាវីដើមបណ្តឹងរដ្ឋប្បវេណី និងព្យាយាមសម្របសម្រួលឲ្យអស់លទ្ធភាពដើម្បីឈានទៅដល់ការឯកភាពជាឯកច្ឆ័ន្ទ ក្នុងការធ្វើជាតំណាងដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងតំណាក់កាលជំនុំជម្រះ »

15. មេធាវីដើមបណ្តឹងរដ្ឋប្បវេណី ទទួលបានតំណាងដោយអាណត្តិពីដើមបណ្តឹងរដ្ឋប្បវេណី ដូច្នេះនិងជាអ្នកត្រូវមានទំនាក់ទំនងជាមួយដើមបណ្តឹងរដ្ឋប្បវេណី។

16. ទាក់ទងនឹងតួនាទីរបស់សហមេធាវីនាំមុខ យោងតាមវិធាន១២ ស្ទួនពីរ (៥)នៃវិធានផ្ទៃក្នុងបានគូសបញ្ជាក់ថា មុខងារដ៏សំខាន់របស់ខ្លួន គឺត្រូវតំណាងផលប្រយោជន៍រួមរបស់ដើមបណ្តឹងរដ្ឋប្បវេណី និងត្រូវធានា«ការទទួលខុសត្រូវជាចុងក្រោយទៅកាន់តុលាការ សម្រាប់ការផ្តល់ការអះអាង និងយុទ្ធសាស្ត្រជាទូទៅ ព្រមទាំងការតំណាងចំពោះមុខតុលាការអំពីផលប្រយោជន៍របស់បណ្តុំដើមបណ្តឹងរដ្ឋប្បវេណីដែលបានរួមគ្នាជាក្រុមតែមួយនោះ ចាប់ពីដំណាក់កាលជំនុំជម្រះឡើងទៅ»។ កថាខ័ណ្ឌ៦ នៃវិធាននេះដដែលបានគូសបញ្ជាក់អំពីការគាំទ្រដ៏មានសារៈសំខាន់របស់មេធាវីដើមបណ្តឹងរដ្ឋប្បវេណី នៅក្រោមទម្រង់ជាការអន្តរាគមន៍ផ្សេងៗ ដែលនេះគឺជាការងារដូចគ្នាក្នុងនាមជាមេធាវី ។

17. វាពិតជាមានសារៈសំខាន់ណាស់ដែល សេចក្តីណែនាំរបស់អង្គជំនុំជម្រះ ត្រូវពិចារណាគ្រប់ពេលវេលាអំពីរបៀបនៃដំណើការដ៏ស្មុគ្រស្មាញនៃក្រុមដើមបណ្តឹងរដ្ឋប្បវេណី។ នៅពេលដែល វិធាន១២ស្ទួនពីរ (៦) ប្រកាសថា « មេធាវីដើមបណ្តឹងរដ្ឋប្បវេណី ត្រូវប្រឹងប្រែងឲ្យអស់លទ្ធភាពដើម្បីផ្តល់ការគាំទ្រដល់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីក្នុងការតំណាងផលប្រយោជន៍ឲ្យបណ្តុំនៃដើមបណ្តឹងរដ្ឋប្បវេណីដែលរួមគ្នាជាក្រុមតែមួយ»។ នេះបញ្ជាក់ឲ្យឃើញថា ការតាក់តែងសារណា ការជ្រើសរើសយុត្តិសាស្ត្រ គឺត្រូវធ្វើរួមគ្នា សហការគ្នានៅក្នុងក្រុម។ បើទោះនៅជាមួយសហមេធាវីនាំមុខក៏ដោយ ក៏វាពិតជាមានសារៈសំខាន់ណាស់ដែលមេធាវីដើមបណ្តឹងរដ្ឋប្បវេណីត្រូវតែទទួលបានការជូនដំណឹងអំពីឯកសារនានា ដែលបានជូនទៅភាគីផ្សេងៗទៀតនោះ។

18. សហមេធាវីនាំមុខ និងមេធាវីដើមបណ្តឹងរដ្ឋប្បវេណី មានមនសិការយល់ដឹងអំពីសារៈសំខាន់ជាសារវន្តនៃការគោរពវិធាននៃការសម្ងាត់ ហេតុដូច្នេះពួកគេនឹងមិនបង្ករជាបញ្ហាលើកិច្ចខិតខំប្រឹងប្រែងកំណត់ជាសម្ងាត់ដែលធ្វើឡើងដោយអង្គជំនុំជម្រះនោះទេ។ ប៉ុន្តែ វាជាការភ្ញាក់ផ្អើលទៅវិញ

នៅពេលដែលអង្គជំនុំជម្រះបាន រិតត្បិតចំពោះការមើលរបាយការណ៍អ្នកជំនាញវេជ្ជសាស្ត្រ សម្រាប់មេធាវីដើមបណ្តឹងរដ្ឋប្បវេណី ក្នុងខណៈដែលមេធាវីការពារក្តីជាង១០នាក់នៃក្រុមផ្សេងៗគ្នា អាចមើលយ៉ាងសេរីទៅវិញ។

19. ដោយមានឋានៈដូចនឹងមេធាវីជនជាប់ចោទ មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីត្រូវតែទទួលបាននូវការប្រព្រឹត្តដូចគ្នា ដើម្បីឲ្យពួកគេអាចបំពេញការងាររបស់ពួកគេបាន។ មេធាវីដើមបណ្តឹងរដ្ឋប្បវេណីមិនត្រូវក្លាយជាកម្មវត្ថុនៃការសង្ស័យដោយឡែក និងការរើសអើងនៅក្នុងការគោរពភាពជាសម្ងាត់នោះទេ។ ដូច្នេះ «វាពិតជាមានសារៈសំខាន់ណាស់ថា គ្រប់ភាគីទាំងអស់មានលទ្ធភាពគាំទ្រ និងប្រឆាំងនឹងការសន្និដ្ឋាននៃជំនាញវេជ្ជសាស្ត្រ»។ អនុស្សរណៈបានរិតត្បិតសិទ្ធិរបស់មេធាវីដើមបណ្តឹងរដ្ឋប្បវេណីដោយបដិសេធពួកគេមិនឲ្យមើលភស្តុតាង ដែលភស្តុតាងទាំងនេះនឹងត្រូវប្រើជាមូលដ្ឋាននៃការតវ៉ារបស់គេ។ ដូចនេះ អង្គជំនុំជម្រះបានធ្វើឲ្យមានការរើសអើងរវាងភាគីខុសៗគ្នា ហើយបានរំលោភវិធាន២១ (១)(ក) នៃវិធានផ្ទៃក្នុង។ វិធាននេះបានបញ្ជាក់យ៉ាងច្បាស់ក្រឡែតអំពីការគោរពសិទ្ធិរបស់ដើមបណ្តឹងរដ្ឋប្បវេណី ៖«អ.វ.ត.ក ត្រូវឃ្លាំមើលនៃការទទួលបានព័ត៌មាន និង ការធានានូវការគោរពសិទ្ធិររបស់ជនរងគ្រោះនៅក្នុងដំណាក់កាលនៃនីតិវិធី។»

20. ដោយសារការរាំងមិនឲ្យមើលឯកសារ សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណី គ្មានលទ្ធភាពក្នុងការបំពេញតួនាទីការពារក្តីរបស់ខ្លួនស្របតាមវិធាន២៣ស្ទួនពីរ(២) និងការការពារនៅក្នុងក្របខណ្ឌរួម ព្រមទាំងគ្មានលទ្ធភាពឈានទៅរកនូវការសំរេចជាឯកច្ឆន្ទតែម្តង ។

21. សេចក្តីសម្រេចដែលមេធាវីដើមបណ្តឹងរដ្ឋប្បវេណីត្រូវសម្រេចនោះអាចផ្ទុះបញ្ចាំងជាមួយគោលការណ៍ដែលបានរៀបរាប់នៅក្នុងវិធាន ២១ (១)(ក) និង (គ)បានប៉ុណ្ណោះគឺវាអាស្រ័យទៅលើថាតើការសម្រេចនេះបានគោរពជាមួយនឹង «ដំណើរការនីតិវិធីនៅក្នុងអង្គជំនុំជម្រះវិសាមញ្ញដែលត្រូវតែយុត្តិធម៌ និង មានការទាញហេតុផលរួមទាំងត្រូវរក្សាបាននូវតុល្យភាពរវាងសិទ្ធិរបស់ភាគីទាំងឡាយ» និងថាតើ « អង្គជំនុំជម្រះវិសាមញ្ញបានជូនព័ត៌មាន និងការធានានូវសិទ្ធិរបស់ជនរងគ្រោះនៅគ្រប់ដំណាក់កាលនៃដំណើរការនីតិវិធីដែរឬទេ ។»

22. ការណ៍ដែលថាបណ្តាមេធាវីដើមបណ្តឹងរដ្ឋប្បវេណីមិនមានសិទ្ធិមើលឯកសារនេះដោយស្មើភាពដូចជាភាគីដទៃទៀតនោះ វាគឺជាការប៉ះពាល់ទៅនឹងគោលការណ៍សមភាពនៃកម្លាំង (égalité des armes)រវាងអ្នកតំណាងរបស់ភាគីផ្សេងៗនៃសំនុំរឿង ។ ដើម្បីមើលវិសាលភាពអនុវត្តនៃគោល

ការណ៍នេះ គេចាំបាច់ត្រូវពិចារណាលើយុត្តិសាស្ត្រអន្តរជាតិ ។ ជាក់ស្តែង នៅក្នុងសំនុំរឿងព្រហ្មទណ្ឌ Delcourt ជំទាស់នឹងប្រទេស ប៊ែលហ្សិក តុលាការសិទ្ធិមនុស្សអ៊ឺរ៉ុប បានសន្និដ្ឋានថា គោលការណ៍សមភាពនៃកម្លាំង (égalité des armes)ផ្តល់ទៅឱ្យគ្រប់ភាគីទាំងអស់នូវការប្រព្រឹត្តស្មើគ្នា ដើម្បីចៀសវាងនូវ «ការបង្កដោយអយុត្តធម៌ចំពោះជនជាប់ចោទនូវស្ថានភាពមិនអនុគ្រោះណាមួយ»[8]។ គោលការណ៍នេះក៏ត្រូវប្រើប្រាស់ផងដែរនៅក្នុងយុត្តសាស្ត្រអន្តរជាតិនៃសំនុំរឿងរដ្ឋអាជ្ញាប្រឆាំងនឹង Dusko Tadic ដោយសាលាឧទ្ធរណ៍នៃតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតយូហ្គោស្លាវីបានសន្និដ្ឋានថា « គោលការណ៍សមភាពនៃកម្លាំង (égalité des armes) តម្រូវឱ្យអង្គភាពតុលាការធានាថា គ្មានភាពណាមួយត្រូវបានដាក់ឱ្យនៅក្នុងស្ថានភាពមិនអនុគ្រោះ នៅខណៈពេលដែលខ្លួនបញ្ជាក់ពីមូលហេតុ»[9]។

23. បណ្តាសេចក្តីណែនាំនៅក្នុងអនុស្សារណៈ E106(E62/3/10)ទាក់ទងនឹងការមើលភស្តុតាងនោះបាន បង្កើតឱ្យមានការបង្វែរនីតិវិធី ដែលកំពុងតែប្រឆាំងនឹងសិទ្ធិរបស់មេធាវីដើមបណ្តឹងរដ្ឋប្បវេណី ដូចដែលមានចែងដោយវិធាន ២៣ស្ទួន (២) និងវិធាន១២ស្ទួន(៣) និង (៦)។

24. ក្នុងគោលបំណងដើម្បីគោរពនូវយុត្តិធម៌នៃនីតិវិធីនៅចំពោះអ.វ.ត.ក និងចំពោះវិធានផ្ទៃក្នុងដែលបានចែងអំពីការដំណាងដើមរដ្ឋប្បវេណីក្រោមទម្រង់រួមនោះ សហមេធាវីនាំមុខស្នើសុំអង្គជំនុំជម្រះសាលាដំបូងឱ្យពិចារណាថា សិទ្ធិរបស់បណ្តាមេធាវីដើមបណ្តឹងរដ្ឋប្បវេណីដែលមាននៅក្នុងវិធានផ្ទៃក្នុងត្រូវបានដកហូត ហើយការរារាំងនេះបណ្តាលឱ្យមេធាវីដើមបណ្តឹងរដ្ឋប្បវេណីគ្មានលទ្ធភាពក្នុងការបំពេញតួនាទីការពាររបស់ខ្លួនតែម្តង។ ចំពោះសហមេធាវីនាំមុខវិញ ក៏ជាការរារាំងសម្រាប់ខ្លួនក្នុងការបំពេញនូវកាតព្វកិច្ចដ៏ចាំបាច់ក្នុងការឈានទៅរកនូវការសម្រេចជាឯកច្ឆ័ន្ទ និងឈានទៅរកភាពជាតំណាងនៃផលប្រយោជន៍រួមរបស់ដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់ផងដែរ។

---

[8] សំនុំរឿងព្រហ្មទណ្ឌ Delcourt ជំទាស់នឹងប្រទេស ប៊ែលហ្សិក តុលាការសិទ្ធិមនុស្សអ៊ឺរ៉ុប សាលដីកាចុះថ្ងៃទី១៧ ខែមករា ឆ្នាំ១៩៧0 សេរីA លេខ១១ កថាខណ្ឌ៣៤

[9] សាលដីការសាលាឧទ្ធរណ៍នៃតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតយូហ្គោស្លាវី ៖ សំនុំរឿង រដ្ឋអាជ្ញា ប្រឆាំងនឹង Dusko Tadic ចុះថ្ងៃទី១៥ កក្កដា ១៩៩៩ IT-94-1-Q **កថាខណ្ឌ** 48 ដល់ 52

សាលាឧទ្ធរណ៍បានបន្ថែមថា«វាតម្រូវឱ្យបកស្រាយនូវគោលការណ៍សមភាពនៃកម្លាំងក្នុងន័យទូលាយនៅក្នុងកប្រខណ្ឌយុត្តិកម្មផ្ទៃក្នុង ។ គោលការណ៍នេះមានន័យថា

ភាគីចោទប្រកាន់និងការពាក្តីជនជាប់ចោទត្រូវតែមានភាពស្មើគ្នានៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង»

25. ជាវិបាក និងជាចម្បង សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីស្នើអង្គជំនុំជម្រះសាលាដំបូងឲ្យកែតំរូវនូវអនុស្សារណៈE62/3/10 ព្រោះអនុស្សារណៈនេះបានបង្កើតនូវរបៀបនៃការមើលឯកសារមួយដែលផ្ទុយទៅនឹងបណ្តាវិធាននានានៃវិធានផ្ទៃក្នុង ។ ដូច្នេះ សហមេធាវីនាំមុខ ស្នើសុំផងដែរឲ្យអង្គជំនុំជម្រះធ្វើការប្រកាសថារបាយការណ៍វេជ្ជសាស្ត្ររបស់អៀង ធីរិទ្ធ និងរបស់នួន ជា នឹងត្រូវជូនដំណឹងទៅសហព្រះរាជអាជ្ញា ទៅមេធាវីរបស់ជនជាប់ចោទម្នាក់ៗ ទៅសហមេធាវីនាំមុខ ព្រមទាំងទៅគ្រប់មេធាវីដើមបណ្តឹងរដ្ឋប្បវេណី ដោយគ្មានការកំហិតអ្វីទាំងអស់ ។

26. ជាលក្ខណៈបន្ទាប់ សហមេធាវីនាំមុខ ស្នើសុំចំពោះបណ្តាមេធាវីដើមបណ្តឹងរដ្ឋប្បវេណីដែលទទួលបានរបាយការណ៍ទាំងនេះមកអំពីខ្លួននោះត្រូវគោរពនូវវិធានដ៏តឹងរ៉ឹងនៃការរក្សាការសម្ងាត់ដែលអនុវត្តនៅក្នុងបរិបទតុលាការ តាមរយៈការអនុវត្តវិធាន១២ ស្ទួនពីរ(៥)និង(៦) ។ សហមេធាវីនាំមុខក៏អាចប្រគល់ឯកសារទាំងនេះដល់គ្រប់មេធាវីដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់ ព្រោះវាជាក់ច្បាស់ណាស់ថាមេធាវីដើមបណ្តឹងរដ្ឋប្បវេណីជាអ្នកដំបូងចូលរួមក្នុងការតាក់តែងនិងសើរើលើសារណាស្តីអំពីរបាយការណ៍វេជ្ជសាស្ត្រទាំងនោះ ។

ធ្វើនៅរាជធានីភ្នំពេញ

| **កាលបរិច្ឆេទ** | **ឈ្មោះ** | **ទីកន្លែង** | **ហត្ថលេខា** |
|---|---|---|---|
| ១៥ កក្កដា ២០១១ | **ពេជ អង្គ**<br>សហមេធាវីនាំមុខជាតិ | ភ្នំពេញ | |
| ១៥ កក្កដា ២០១១ | **Elisabeth SIMONNEAU-Fort**<br>សហមេធាវីនាំមុខអន្តរជាតិ | | |
| ១៥ កក្កដា ២០១១ | **ម៉ុច សុវណ្ណារី**<br>សហមេធាវីជាតិ | | |
| ១៥ កក្កដា ២០១១ | **គីម ម៉េងឃី**<br>សហមេធាវីជាតិ | | |
| ១៥ កក្កដា ២០១១ | **Isabelle DURAND**<br>សហមេធាវីអន្តរជាតិ | | |